# « វិសេសលើសជាងអ្នកដែលមានជ័យជំនះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង »

អែលឌើរ ផល វី ចនសុន
នៃពួកចិតសិបនាក់

*ការសាកល្បងទាំងនេះគឺពុំមែនគ្រាន់តែដើម្បីពិសោធន៍យើងនោះទេ ។ វាមានសារៈសំខាន់ចំពោះដំណើរការនៃការដាក់បន្ថែមនូវនិស្ស័យនៃព្រះ ។*

ជីវិតលើផែនដីរួមមាននូវការសាកល្បង ទុក្ខវេទនា និងការសាកល្បងមួយចំនួនដែលជួយក្នុងជីវិតអាចជារឿងដ៏ឈឺចាប់ ។ មិនថាវាជាជំងឺ ការក្បត់ ការល្បួង ការបាត់បង់មនុស្សជាទីស្រឡាញ់ គ្រោះធម្មជាតិ ឬរឿងអាក្រក់មួយចំនួនផ្សេងទៀតក្តី ការរងទុក្ខគឺជាផ្នែកនៃជីវិតរមែងស្លាប់យើង ។មានមនុស្សជាច្រើនឆ្ងល់ថា ហេតុអ្វីយើងត្រូវជួបឧបសគ្គដ៏លំបាកទាំងនេះ ។ យើងដឹងថាហេតុផលមួយគឺសាកល្បងដល់ក្តីជំនឿយើង ដើម្បីឃើញថា យើងនឹងធ្វើរាល់កិច្ចការដែលព្រះអម្ចាស់បានដាក់បញ្ជាដែរឬអត់ ។[1]ដោយសំណាងល្អ ជីវិតលើផែនដីនេះគឺជាកន្លែងដ៏ល្អបំផុតដើម្បីជួប ---ហើយឈ្នះ...នូវការពិសោធន៍ទាំងនេះ ។[2]

តែការសាកល្បងទាំងនេះគឺពុំមែនគ្រាន់តែដើម្បីពិសោធន៍យើងនោះទេ ។ វាមានសារៈសំខាន់ចំពោះដំណើរការនៃការដាក់បន្ថែមនូវនិស្ស័យនៃព្រះ ។[3] បើយើងទ្រាំទ្រការលំបាកទាំងនេះបានត្រឹមត្រូវ វានឹងក្លាយទៅជារង្វាន់សម្រាប់យើងវិញ ។[4]

អែលឌើរ អ័រសិន អេហ្វ វីតនី បាននិយាយថា « គ្មានការឈឺចាប់ ឬការសាកល្បងណាមួយដែលយើងជួបគឺជារឿងឥតប្រយោជន៍ឡើយ ... ។ រាល់អ្វីៗដែលយើងបានរងទុក្ខ និងបានស៊ូទ្រាំ ជាពិសេសពេលយើងស៊ូទ្រាំវាដោយអត់ធ្មត់ នោះវានឹងពង្រឹងគុណសម្បត្តិយើង ធ្វើឲ្យចិត្តយើងបរិសុទ្ធ ពង្រីកព្រលឹងយើង និងធ្វើឲ្យយើងទន់ភ្លន់និងមានក្តីសប្បុរសជាងមុន ...ហើយតាមរយៈភាពសោកសៅ និងការរងទុក្ខ ការលំបាក និងទុក្ខវេទនានេះហើយ ទើបយើងទទួលចំណេះដឹងថាយើងមកក្នុងជីវិតនេះដើម្បីទទួលវា » ។[5]

ថ្មីៗនេះ មានក្មេងប្រុសអាយុប្រាំបួនឆ្នាំម្នាក់ជួបនឹងជំងឺមហារីកឆ្អឹងដែលកម្រឃើញ ។ គ្រូពេទ្យបានពន្យល់ពីការវិនិច្ឆ័យរោគ និងការព្យាបាល ដែលរួមបញ្ចូលនូវវិធីព្យាបាលដោយប្រើគីមីជាច្រើនខែ និងការវះកាត់ធំ ។គាត់និយាយថា វាគឺជាពេលដ៏លំបាកសម្រាប់ក្មេងប្រុសនោះ និងគ្រួសារគេ តែគាត់បានបន្ថែមថា « មានមនុស្សបានសួរខ្ញុំថា ‹ បន្ទាប់ពីនេះទៅតើខ្ញុំនឹងនៅដូចដើមមែនទេ ? › ខ្ញុំប្រាប់គេថា ‹ ទេ អ្នកនឹងមិនដូចដើមឡើយ ។ អ្នកនឹងមានកម្លាំងជាងមុន ។ អ្នកនឹងមានភាពរឹងមាំ ! › »

ពេលខ្លះ ការសាកល្បងរបស់យើងហាក់ដូចជាត្រូវបានផ្តោតលើផ្នែកនៃជីវិត និងព្រលឹងយើងជាមួយនឹងអ្វីដែលយើងហាក់ដូចជាខ្វះលទ្ធភាពនឹងស៊ូទ្រាំ ។ដោយសារការរីកចម្រើនផ្ទាល់ខ្លួនគឺជាលទ្ធផលមួយនៃឧបសគ្គទាំងនេះ វាពុំគួរជារឿងគួរឲ្យភ្ញាក់ផ្អើលឡើយ ថាការសាកល្បងទាំងនេះជារឿងផ្ទាល់ខ្លួន ---គឺវាហាក់ដូចជាពាក់ព័ន្ធនឹងក្តីត្រូវការ ឬភាពទន់ខ្សោយជាក់លាក់របស់យើង ។ ហើយគ្មាននរណាម្នាក់អាចគេចផុតឡើយ សូម្បីតែពួកបរិសុទ្ធដែលខំព្យាយាមធ្វើការល្អក្តី ។ មានពួកបរិសុទ្ធដ៏ត្រឹមត្រូវមួយចំនួនបានសួរថា « ហេតុអ្វីបានជាខ្ញុំទៅវិញ ? ខ្ញុំខំព្យាយាមធ្វើល្អ ! ហេតុអ្វីព្រះអម្ចាស់បណ្តោយឲ្យរឿងនេះកើតឡើង ? » ឡកម្តៅនៃការលំបាក[6] ជួយធ្វើឲ្យបរិសុទ្ធ សូម្បីតែពួកបរិសុទ្ធដ៏ល្អបំផុតក្តី ដោយជួយយើងដកយកភាពមិនបរិសុទ្ធក្នុងជីវិតយើងចេញ ហើយធ្វើឲ្យយើងបរិសុទ្ធជាងមុន ។

សូម្បីតែរ៉ែដ៏មានតម្លៃបំផុតក៏ត្រូវចម្រាញ់យកភាពមិនបរិសុទ្ធចេញដែរ ។ ការធ្វើល្អមិនគ្រប់គ្រាន់ទេ ។ យើងចង់ប្រែក្លាយដូចជាព្រះអង្គសង្គ្រោះ ជាអង្គដែលបានរៀនក្នុងពេលទ្រង់រងការឈឺចាប់ និងការលំបាក និងការល្បួងគ្រប់យ៉ាង ។[7]

ផ្លូវលំ គ្រីមសិននៅជ្រលងភ្នំ លូហ្គិន គឺជាកន្លែងមួយដែលខ្ញុំចូលចិត្ត ។ ផ្នែកដ៏សំខាន់នៃផ្លូវលំនោះគឺមានខ្យល់បក់នៅតាមកំពូលថ្មចោទខ្ពស់ ហើយអាចមានឃើញទេសភាពដ៏ស្អាតនៃជ្រលងជ្រោះ និងជ្រលងភ្នំខាងក្រោម ។ តែការឡើងទៅកំពូលថ្មចោទពុំមែនរឿងងាយឡើយ ។ ផ្លូវលំនោះមានផ្លូវឡើងមួយ ហើយពីមុនឡើងដល់កំពូល នោះអ្នកឡើងភ្នំនឹងជួបនូវផ្នែកដ៏ចោតបំផុតនៃផ្លូវលំនោះ ហើយទេសភាពនៃជ្រលងជ្រោះត្រូវបានបិទបាំងដោយថ្មចោទទាំងនោះ ។ ការខិតខំនៅចុងបញ្ចប់គឺមានតម្លៃណាស់ ពីព្រោះពេលទៅដល់កំពូលគឺបានឃើញនូវទេសភាពដ៏អស្ចារ្យ ។ វិធីតែមួយគត់ដើម្បីឃើញទេសភាពនោះគឺត្រូវតោងឡើងតាមភ្នំ ។

គន្លងមួយក្នុងបទគម្ពីរនិងក្នុងជីវិតបង្ហាញថា ភាគច្រើន ការពិសោធន៍ដ៏គ្រោះថ្នាក់ និងងងឹតបំផុត បានបង្កើតជាព្រឹត្តិការណ៍ និងការរីកចម្រើនដ៏អស្ចារ្យភ្លាមៗ ។ « បន្ទាប់ពីការវេទនាដ៏ច្រើន នោះទើបបានព្រះពរ » ។[8] កូនចៅអ៊ីស្រាអែលត្រូវបានរាំងដោយទន្លេក្រហមពីមុនវាត្រូវបានញែកចេញជាពីរ ។[9] នីហ្វៃបានជួបនឹងគ្រោះថ្នាក់ ត្រូវបានបងប្រុសខឹង និងជួបការបរាជ័យជាច្រើនពីមុនគាត់អាចយកបានផ្ទាំងលង្ហិន ។[10] យ៉ូសែប ស្ម៊ីធ ត្រូវបានគ្របសង្កត់ដោយអំណាចអាក្រក់យ៉ាងអស្ចារ្យ ដែលមើលទៅហាក់ដូចជាគាត់បានស្ថិតក្នុងការបំផ្លិចបំផ្លាញទាំងស្រុង ។

ពេលគាត់រៀបនឹងលិចលង់ក្នុងការអស់សង្ឃឹម គាត់បានខំអស់ពីសមត្ថភាពដើម្បីអំពាវនាវដល់ព្រះ ហើយខណៈពេលនោះគាត់បានឃើញព្រះវរបិតា និងព្រះរាជបុត្រា ។ [11] ជារឿយៗ ពួកអ្នករៀនថ្មីជួបនឹងរឿងជំទាស់ និងការលំបាក ពេលគេជិតធ្វើបុណ្យជ្រមុជទឹក ។ ម្ដាយគ្រប់រូបដឹងថា ការលំបាកក្នុងការបង្កើតកូននាំមកនូវអព្ភូតហេតុនៃការចាប់កំណើត ។ ម្ដងហើយម្ដងទៀត យើងឃើញពីពរជ័យដ៏អស្ចារ្យដែលកើតមានតាមក្រោយនៃការសាកល្បងធំៗទាំងឡាយ ។

កាលពីជីដូនខ្ញុំនៅអាយុ19 ឆ្នាំ គាត់បានកើតជំងឺមួយដែលធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ក្រោយមកគាត់បាននិយាយថា « យាយដើរមិនរួច ។ ជើងឆ្វេងយាយមានភាពទន់ខ្សោយក្រោយពីសម្រាកនៅលើគ្រែជាច្រើនខែ ។ ឆ្អឹងទាំងអស់ទន់ដូចជាអេប៉ុង ហើយពេលយាយដាក់ជើងយាយប៉ះនឹងឥដ្ឋវាមានអារម្មណ៍ដូចជាភ្លើងឆក់អញ្ចឹង» ។[12] ខណៈដែលគាត់ត្រូវសម្រាកនៅលើគ្រែ ហើយការរងទុក្ខរបស់គាត់កាន់តែខ្លាំងឡើយ គាត់បានទទួល និងបានសិក្សាពីកូនសៀវភៅសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ គាត់ត្រូវបានផ្លាស់ប្រែចិត្តជឿ ហើយក្រោយមកបានជ្រមុជទឹក ។ ភាគច្រើនឧបសគ្គដ៏ជាក់លាក់មួយជួយរៀបចំយើងសម្រាប់អ្វីមួយដែលសំខាន់បំផុត ។

ការហ៊ុមព័ទ្ធដោយបញ្ហានានា វាពិបាកនឹងមើលឃើញនូវពរជ័យដ៏ធំដែលនឹងកើតមានលើសពីការឈឺចាប់ ភាពអាម៉ាស់ ឬការខូចចិត្តដែលយើងអាចជួបនៅពេលនោះណាស់ ។ « កាលណាយើងត្រូវសេចក្ដីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមក នោះទើបបង្កើតផលដ៏សុខសាន្តនៃសេចក្ដីសុចរិតដល់អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ » ។ [13] សាវកប៉ុលបានបង្រៀនថា « ត្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងមានសិរីល្អយ៉ាងធ្ងន់លើសលប់ដ៏នៅអស់កល្បជានិច្ចវិញ » ។ [14] វាគួរឲ្យចាប់អារម្មណ៍ណាស់ដែលប៉ុលបានប្រើពាក្យ « ទុក្ខលំបាកយ៉ាងស្រាល » នោះ ។ ពាក្យនេះមកពីមនុស្សម្នាក់ដែលត្រូវបានគេវាយ គេចោលនឹងដុំថ្ម ចាប់ចង ឃុំឃាំង និងបានពិសោធន៍នូវការសាកល្បងច្រើនផ្សេងទៀត ។ [15] ខ្ញុំជឿថា យើងគ្រប់គ្នានឹងមិនគិតថាទុក្ខលំបាកយើងជារឿងស្រាលនោះទេ ។ តែបើប្រៀបធៀបនឹងពរជ័យ និងការរីកចម្រើនដែលយើងនឹងទទួល ទាំងក្នុងជីវិតនេះនិងក្នុងភាពអស់កល្ប ទុក្ខលំបាកយើងគឺពិតជាស្រាលមែន ។

យើងមិនចង់បាននូវការពិសោធន៍ ការសាកល្បង និងទុក្ខវេទនាឡើយ ។ ដំណើររបស់យើងក្នុងជីវិតនេះនឹងនូវចំនួនដ៏ត្រឹមត្រូវមួយសម្រាប់តម្រូវការយើង ។ ការសាកល្បងជាច្រើនគឺជាផ្នែកខាងធម្មជាតិមួយនៃជីវិតរមែងស្លាប់យើង តែវាដើរតួយ៉ាងសំខាន់នៅក្នុងការរីកចម្រើនរបស់យើង ។

ពេលការបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងជីវិតរមែងស្លាប់មុននឹងបញ្ចប់ ទ្រង់បានពិសោធន៍នូវការសាកល្បងដ៏លំបាកបំផុត ---ជាការរងទុក្ខដ៏មហិមាក្នុងសួនច្បារគេតសាម៉ានី និងនៅលើភ្នំគាល់កូថា ។ ការណ៍នេះបាននាំមកនូវការរស់ឡើងវិញដ៏រុងរឿង និងការសន្យាថា រាល់ការរងទុក្ខរបស់យើង នឹងត្រូវបានបញ្ចប់នៅថ្ងៃណាមួយ ។ ការរងទុក្ខទ្រង់គឺជាការចាំបាច់ចំពោះផ្នូរទទេស្អាតនៅព្រឹកបុណ្យអ៊ីស្ទើរនោះ និងចំពោះជីវិតអមត និងអស់កល្បនាអនាគតរបស់យើង ។

ពេលខ្លះ យើងចង់រីកចម្រើនដោយពុំមានជួបឧបសគ្គ ហើយចង់អភិវឌ្ឍភាពរឹងមាំដោយគ្មានជួបនូវបញ្ហា ។ តែការរីកចម្រើនមិនអាចកើតឡើងដោយងាយៗបានឡើយ ។យើងយល់យ៉ាងច្បាស់ថា កីឡាករម្នាក់ដែលអាចស៊ូទ្រាំនឹងការហ្វឹកហាត់ដ៏លំបាកបាន នឹងមិនក្លាយជាកីឡាករលំដាប់ថ្នាក់ពិភពលោកឡើយ ។ យើងត្រូវតែប្រុងប្រយ័ត្នថា យើងមិនអន់ចិត្តនឹងរឿងទាំងឡាយដែលជួយយើងឲ្យមាននូវនិស្ស័យនៃព្រះ ។

គ្មានការសាកល្បង និងទុក្ខវេទនាណាមួយដែលយើងជួប គឺហួសពីសមត្ថភាពយើងឡើយ ពីព្រោះយើងមានជំនួយពីព្រះអម្ចាស់ ។ យើងអាចធ្វើរឿងគ្រប់យ៉ាងតាមរយៈព្រះគ្រីស្ទ ជាអង្គដែលពង្រឹងដល់យើង ។[16]

បន្ទាប់ពីជាសះស្បើយពីបញ្ហាសុខភាពដ៏ធ្ងន់ អែលឌើរ រ៉ូបឺត ឌី ហែល បានចែកចាយនូវពាក្យពេចន៍ដូចតទៅនេះក្នុងសន្និសីទទូទៅ ៖ « មានពេលខ្លះ ខ្ញុំបានទូលប្រាប់ព្រះអម្ចាស់ថា ខ្ញុំពិតជាបានរៀនមេរៀនដែលបានបង្រៀនហើយ ហើយថាមិនចាំបាច់ឲ្យខ្ញុំត្រូវស៊ូទ្រាំនឹងការរងទុក្ខច្រើនទៀតឡើយ ។

សំណើបែបនេះហាក់ដូចជាគ្មានបានលទ្ធផលសោះ ព្រោះខ្ញុំបានដឹងយ៉ាងច្បាស់ថា ដំណើរការនៃការពិសោធន៍នេះត្រូវតែធ្វើឡើងស្របទៅតាមពេលវេលា និងតាមវិធីរបស់ព្រះអម្ចាស់ ។ ខ្ញុំ ...បានរៀនថា ខ្ញុំនឹងមិនត្រូវបានទុកចោលឲ្យប្រឈមមុខនឹងការសាកល្បង និងទុក្ខវេទនានេះតែម្នាក់ឯងឡើយ តែពួកទេវតានឹងជួយដល់ខ្ញុំ ។ មានមនុស្សមួយចំនួនអាចប្រៀបនឹងពួកទេវតាដែលស្ថិតនៅក្នុងទម្រង់ជាគ្រូពេទ្យ ជាគិលានុបដ្ឋាយិកា និងលើសពីនេះទៅទៀត គឺ ម៉ារី ដែលជាភរិយាដ៏ទន់ភ្លន់របស់ខ្ញុំ ។ ហើយពេលព្រះអម្ចាស់សព្វព្រះទ័យ ខ្ញុំត្រូវបានលួងលោមដោយការយាងមកនៃពួកទេវតាសួគ៌ដែលនាំមកនូវការលួងលោម និងការអះអាងដ៏អស់កល្បក្នុងគ្រាដ៏ចាំបាច់របស់ខ្ញុំ » ។[17]

ព្រះវរបិតាសួគ៌យើងស្រឡាញ់យើង ហើយយើងដឹង « នរណាដែលដាក់ទីទុកចិត្តរបស់ខ្លួនទៅលើព្រះ អ្នកនោះហើយ ដែលនឹងបានគាំទ្រនៅក្នុងការពិសោធន៍របស់គេ និងវិបត្តិរបស់គេ និងការរងទុក្ខវេទនារបស់គេ ហើយនឹងត្រូវបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់ » ។[18] នៅថ្ងៃណាមួយពេលយើងចាកចេញពីជីវិតនេះទៅ យើងចង់បានលើសពីអ្វីដែលមនុស្សម្នាក់នឹងប្រាប់ដល់យើងថា « អ្នកបានចប់ហើយ » ។ តែយើងចង់ឲ្យព្រះអម្ចាស់មានបន្ទូលថា « ប្រពៃហើយ បាវល្អស្មោះត្រង់អើយ » ។[19]

ខ្ញុំចូលចិត្តពាក្យរបស់ប៉ុលថា ៖ « តើអ្នកណានឹងពង្រាត់យើងចេញពីសេចក្ដីស្រឡាញ់របស់ផងព្រះគ្រីស្ទបាន ? តើសេចក្ដីទុក្ខលំបាក ឬសេចក្ដីវេទនា សេចក្ដីបៀតបៀន សេចក្ដីអត់ឃ្លាន សេចក្ដីអាក្រាត សេចក្ដីអន្តរាយ ឬដាវឬអី ? ...

« ទេ គឺក្នុងសេចក្ដីទាំងនោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យ
ជំនះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង » ។ [20]

ខ្ញុំដឹងថា ព្រះ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មានព្រះជន្មរស់ ។ ខ្ញុំក៏ដឹងថា តាមរយៈជំនួយរបស់ទ្រង់ទាំងពីរអង្គ យើងអាច « វិសេសជាងអ្នកដែលមានជ័យជំនះទៅទៀត » នៅក្នុងទុក្ខវេទនាដែលយើងជួបក្នុងជីវិតនេះ ។ យើងអាចប្រែក្លាយដូចជាទ្រង់ទាំងពីរអង្គ ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល ពេត្រុសទី 1 1: 6–8 អ័ប្រាហាំ 3:25 ។
2. សូមមើល ពេត្រុសទី 1 2:20 ។
2. សូមមើល ពេត្រុសទី 2:20 ។
4. សូមមើល នីហ្វៃទី 2 2:2 ។
5. បានដកស្រង់ក្នុងSpencer W. Kimball, *Faith Precedes the Miracle* (ឆ្នាំ 1972) ទំព័រ 98 ។
6. អេសាយ 48:10 នីហ្វៃទី 1 20:10 ។
7. សូមមើល អាលម៉ា 7:11–12 ។
8. គោលលទ្ធិ និងសេចក្ដីសញ្ញា 58:4 ។
9. សូមមើល និក្ខមនំ 14:5–30 ។
10. សូមមើល នីហ្វៃទី 1 3–4។
11. សូមមើល យ.ស.---ប្រវត្តិ 1:15–17 ។
12. Amalie Hollenweger Amacher, unpublished history in possession of author ។
13. ហេព្រើរ 12:11 ។
14. កូរិនថូសទី 2 4:17 ។
15. សូមមើល កូរិនថូសទី 2  11:23–28 ។
16. សូមមើល ភីលីព 4:13 ។
17. Robert D. Hales, « The Covenant of Baptism: To Be in the Kingdom and of the Kingdom » *Ensign* ខែ វិច្ឆិកា ឆ្នាំ 2000 ទំព័រ 6 ។
18. អាលម៉ា 36:3 ។
19. ម៉ាថាយ25:21 ។
20. រ៉ូម 8:35, 37 ។